International Labour Organization | BetterWork | Cornell University ILR School

ILO brief

# គម្រោងការងារសមរម្យក្នុងសង្វាក់ផ្គត់ផ្គង់សំលៀកបំពាក់ក្នុងតំបន់អាស៊ី

ខែ ឧសភា ឆ្នាំ២០២១

## សំលៀកបំពាក់បៃតង? គំនិតផ្តួចផ្តើម និងឧបករណ៍បរិស្ថានក្នុងវិស័យកាត់ដេរនៅតំបន់អាស៊ី

ការកើនឡើងនៃផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថានដោយសារសង្វាក់ផ្គត់ផ្គង់វាយនភណ្ឌ និងកាត់ដេរ ត្រូវបានកត់សម្គាល់យ៉ាងទូលំទូលាយ និងនាំទៅរកការបង្កើតគំនិតផ្តួចផ្តើម ឧបករណ៍ និងវេទិកាវាយតម្លៃជាច្រើនដើម្បីបង្កើននិរន្តរភាពនៃវិស័យនេះ។ គំនិតផ្តួចផ្តើមទាំងនេះពោរពេញដោយលក្ខណៈចម្រុះគ្នា ដូចជាភាពខុសគ្នានៃចំណុចផ្តោត តួអង្គពាក់ព័ន្ធ អ្នកទទួលផល ភាពយូរអង្វែងនៃសកម្មភាព និងរបៀបដែលសកម្មភាពទាំងនោះកំណត់ និងវាស់វែងភាពជោគជ័យ។ របាយការណ៍គូសបញ្ជាក់ពីផ្នែកដែលអាចមានគម្លាតក្នុងគំនិតផ្តួចផ្តើមបច្ចុប្បន្ន និងប្រភេទគំនិតផ្តួចផ្តើមដែលបន្សីគ្នានឹងចំណេះដឹងស្តីពីសហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យម (MSMEs) និងតម្រូវការរៀនសូត្រ សម្រាប់ជាវិធីគូសបញ្ជាក់ពីផ្នែកដែលគួរផ្តោតការយកចិត្តទុកដាក់ក្នុងការបង្កើតគំនិតផ្តួចផ្តើមថ្មី ឬគំនិតផ្តួចផ្តើមបន្ថែម។

ការកើនឡើងនៃផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថានដោយសារសង្វាក់ផ្គត់ផ្គង់វាយនភណ្ឌ និងកាត់ដេរ ត្រូវបានកត់សម្គាល់យ៉ាងទូលំទូលាយ និងនាំទៅរកការបង្កើតគំនិតផ្តួចផ្តើម ឧបករណ៍ និងវេទិកាវាយតម្លៃជាច្រើនដើម្បីបង្កើននិរន្តរភាពនៃវិស័យនេះ។ គំនិតផ្តួចផ្តើមទាំងនេះពោរពេញដោយលក្ខណៈចម្រុះគ្នា ដូចជាភាពខុសគ្នានៃចំណុចផ្តោត តួអង្គពាក់ព័ន្ធ អ្នកទទួលផល ភាពយូរអង្វែងនៃសកម្មភាព និងរបៀបដែលសកម្មភាពទាំងនោះកំណត់ និងវាស់វែងភាពជោគជ័យ។ សម្រាប់អ្នកពាក់ព័ន្ធជាច្រើនក្នុងតំបន់អាស៊ី ចំនួន និងនានាភាពនៃគំនិតផ្តួចផ្តើម បានបង្កការភាន់ច្រលំ។ របាយការណ៍នេះមានគោលបំណងពីរ។ ទីមួយ គឺការវិភាគគំនិតផ្តួចផ្តើមជាឧទាហរណ៍ទាំងនេះ ពាក់ព័ន្ធនឹងវិសាលភាពភូមិសាស្ត្រ និងវិស័យ អ្នកចូលរួមគោលដៅ គំនូរប្រតិបត្តិការ មធ្យោបាយ អន្តរាគមន៍ វិមាត្រ ភាពជោគជ័យ និងភាពអាចអនុវត្តតាមបាន ដើម្បីកំណត់រកផ្នែក និងរបៀបដែលគំនិតផ្តួចផ្តើមទាំងនេះអាច និងកំពុងបង្កើននិរន្តរភាពបរិស្ថានក្នុងវិស័យកាត់ដេរ និងកំណត់រកថាតើមានគម្លាតក្នុងគំនិតផ្តួចផ្តើម ឬទេ និងត្រង់ចំណុចណាខ្លះ។ ទីពីរគឺការសិក្សាពីវិសាលភាព និងភាពគ្របដណ្តប់នៃគំនិតផ្តួចផ្តើមបរិស្ថានលើសហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យម (MSMEs) ក្នុងវិស័យនេះ។ មតិយោបល់តាមវិស័យលើកឡើងថាក្រុមហ៊ុនខ្នាតតូចជា “អ្វីដែលត្រូវបានមើលរំលង-blind spot” ក្នុងការសម្រេចបាននិរន្តរភាពប្រសើរជាងមុន។ ដូច្នេះ របាយការណ៍នេះនឹងពិនិត្យមើលភាពត្រួតគ្នានៃគំនិតផ្តួចផ្តើមទាំងនេះជាមួយនឹងចលករថ្មីៗក្នុងសហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យម។ បញ្ហានិរន្តរភាពរបស់ក្រុមហ៊ុនខ្នាតតូចគឺដូចក្រុមហ៊ុនផ្សេងទៀតដែរ ប៉ុន្តែដោយសារក្រុមហ៊ុនទាំងនេះមានទំហំតូច (និងមានធនធានមនុស្ស និងហិរញ្ញវត្ថុតិច) និងតួនាទីបន្ទាប់បន្សំក្នុងសង្វាក់ផ្គត់ផ្គង់ (មិនសូវមានលទ្ធភាពទទួលបានចំណេះដឹង និងចំណេះធ្វើ) ធ្វើឱ្យបញ្ហាប្រឈមទាំងនេះកាន់តែលំបាកដោះស្រាយ។

ការវិភាគក្នុងរបាយការណ៍នេះរកឃើញគំរូប្រតិបត្តិការ ៣ កម្រិត ក្នុងគំនិតផ្តួចផ្តើមនិរន្តរភាពបរិស្ថានទាំងនេះ ៖

**១.** ស្តង់ដារអនុវត្តន៍ការងារ ៖ ជាទូទៅ មានការផ្តល់វិញ្ញាបនបត្រ និងពេលខ្លះមានសកម្មភាពកសាងសមត្ថភាព។

**២.** ការផ្តល់កម្មវិធី ៖ កម្មវិធីសកម្មភាពដែលមានថិរវេលាកំណត់ ជាទូទៅរួមមានកិច្ចសន្ទនានៅកម្រិតក្រុមហ៊ុនម្ចាស់ម៉ាក និងការបង្កើតឧបករណ៍/ការណែនាំ សវនកម្មនៅកម្រិតរោងចក្រ និងសកម្មភាពជំរុញការចូលរួម ការវិភាគប្រព័ន្ធគោលនយោបាយ និងការតស៊ូមតិ និងលទ្ធភាពទទួលបានហិរញ្ញវត្ថុសម្រាប់ការវិនិយោគនិរន្តរភាព និង

៣. កិច្ចសន្ទនាសង្គម ការចែករំលែកចំណេះដឹង និងការតស៊ូមតិ ៖ គំនិតផ្តួចផ្តើមទាំងនេះផ្តោតលើកិច្ចសន្ទនាសង្គម និងសកម្មភាពចែករំលែកចំណេះដឹងទៅមកក្នុងក្នុងសង្វាក់ផ្គត់ផ្គង់។ ជាទូទៅ សកម្មភាពទាំងនេះផ្សារភ្ជាប់នឹងគោលដៅនិរន្តរភាពទូលំទូលាយ ដូចជា គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការកំណត់បរិបទនៃគោលដៅទាំងនេះសម្រាប់វិស័យវាយនភណ្ឌ និងកាត់ដេរ។ ជាទូទៅ គំនិតផ្តួចផ្តើមទាំងនេះដើរតួនាទីសំខាន់សម្រាប់កិច្ចសន្ទនាពហុភាគី។

នៅពេលវិភាគរបៀបដែលគំនិតផ្តួចផ្តើមទាំងនេះត្រួតគ្នានឹងឧបសគ្គ និងកត្តាជំរុញនវានុវត្តន៍បែបមេត្រីភាពបរិស្ថានក្នុងសហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យម យើងរកឃើញឧបសគ្គរារាំងការអនុវត្តនវានុវត្តន៍បែបមេត្រីភាពបរិស្ថាន ដូចខាងក្រោម ៖

- កង្វះការយល់ដឹងស្តីពីបញ្ហាបរិស្ថាន និងផលប៉ះពាល់របស់វា រួមទាំងផលប៉ះពាល់សង្គម
- កង្វះការយល់ដឹងអំពីជម្រើសសម្រាប់នវានុវត្តន៍បែបមេត្រីភាពបរិស្ថាន និងរបៀបដាក់បញ្ចូលនវានុវត្តន៍ទាំងនោះក្នុងសកម្មភាពរៀបចំផែនការអាជីវកម្មជាយុទ្ធសាស្ត្រ និងរួមចំណែកដល់ភាពប្រកួតប្រជែង និងផលិតភាព
- កង្វះការយល់ដឹងស្តីពីការទទួលខុសត្រូវចំពោះការអនុលោមតាមបទបញ្ញត្តិបរិស្ថាន និងចំណេះធ្វើក្នុងការវិនិយោគលើវិធានការលើសពីអនុលោមភាព
- កង្វះលទ្ធភាពប្រឡូកក្នុងបណ្តាញផ្ទេរចំណេះដឹង និងជំនាញ ៖ ការពិនិត្យមើលរបៀបអនុវត្តការអនុវត្តល្អបំផុតក្នុងអាជីវកម្មផ្សេងទៀត និងសមត្ថភាពក្នុងការសម្របតាម និងអនុវត្ត
- គម្លាតទំនាក់ទំនងក្នុងសង្វាក់ផ្គត់ផ្គង់
- ឧបសគ្គក្នុងការទទួលបានហិរញ្ញវត្ថុ
- ហេដ្ឋារចនាសម្ព័ន្ធអន់ថយ ដូចជា លទ្ធភាពប្រើប្រាស់ប្រព័ន្ធទឹកស្អាត និងប្រព័ន្ធចម្រោះទឹកស្អុយ។

គំនិតផ្តួចផ្តើមទាំងអស់ដែលត្រូវបានវិភាគក្នុងរបាយការណ៍នេះ មិនផ្តោតសំខាន់លើសហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យមឡើយ ហើយខណៈដែលគំរូប្រតិបត្តិការទាំង ៣ ខាងលើ មិនផាត់ចេញសហគ្រាសទាំងនោះ មានលក្ខណៈជាច្រើនក្នុងគំរូនីមួយៗដែលអាចរឹតត្បិតការអនុវត្តដោយក្រុមហ៊ុនទាំងនេះ ៖

- ពាក់ព័ន្ធនឹងគំរូស្តង់ដារអនុវត្តន៍ការងារ សហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យម ហាក់មិនសូវមានសមត្ថភាពផ្ទៃក្នុងការស្រូបយក ដើម្បីពាំនាំ ដាក់បញ្ចូល និងប្រើប្រាស់ស្តង់ដារអនុវត្តន៍ការងារតាមរបៀបដែលបង្កើតនិរន្តរភាពបរិស្ថានរបស់ក្រុមហ៊ុន។
- ពាក់ព័ន្ធនឹងគំរូផ្តល់កម្មវិធី ប្រសិនបើសហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យម ស្ថិតក្នុងក្រុមគោលដៅសម្រាប់គំនិតផ្តួចផ្តើមនេះ សហគ្រាសនោះនឹងទទួលបានអត្ថប្រយោជន៍ពីគំរូនេះ ព្រោះកម្មវិធីទាំងនេះផ្តល់ការកសាងសមត្ថភាព សវនកម្ម និងដំបូន្មានសម្រាប់ការកែលម្អ លទ្ធភាពទទួលបានហិរញ្ញវត្ថុ និងការតស៊ូមតិជាមួយអ្នកតាក់តែងគោលនយោបាយ ដើម្បីដោះស្រាយឧបសគ្គមិនមែនទីផ្សារផ្សេងទៀត។ ប៉ុន្តែដោយសារតែគំនិតផ្តួចផ្តើមទាំងនេះត្រូវការធនធានយ៉ាងច្រើន មានក្រុមហ៊ុនតិចតួចប៉ុណ្ណោះដែលអាចទទួលបានអត្ថប្រយោជន៍ ហើយក្រុមហ៊ុនទាំងនោះមិនទទួលបានជំនួយទ្រង់ទ្រាយធំសម្រាប់ការផ្លាស់ប្តូរទូលំទូលាយនៅកម្រិតប្រព័ន្ធឡើយ។
- ពាក់ព័ន្ធនឹងគំរូកិច្ចសន្ទនាសង្គម ការចែករំលែកចំណេះដឹង និងការតស៊ូមតិ ខណៈដែលគំរូនេះមានប្រយោជន៍សម្រាប់ការចែករំលែក "ការអនុវត្តល្អបំផុត" មានដែនកំណត់ពាក់ព័ន្ធនឹងអ្នកដែលត្រូវបានដាក់បញ្ចូលក្នុងកិច្ចសន្ទនា និងអ្វីដែលគេចាត់ទុកជា "ការអនុវត្តល្អបំផុត"។

គំនិតផ្តួចផ្តើមតាមវិស័យដើរតួនាទីសំខាន់ក្នុងការសម្របសម្រួលសកម្មភាពនិរន្តរភាពក្នុងវិស័យវាយនភណ្ឌ និងកាត់ដេរ។ គំនិតផ្តួចផ្តើមទាំងនេះជាទម្រង់មួយនៃយន្តការអភិបាលកិច្ចតាមវិស័យដែលកំណត់ពីការអនុវត្តល្អ និងរបៀបសម្រេចបានអនុវត្តល្អ។ ទោះជាយ៉ាងណា មានដែនកំណត់ក្នុងយន្តការទាំងនេះ ៖ គំរូប្រតិបត្តិការនីមួយៗមានដែនកំណត់ក្នុងវិសាលភាព ភាពគ្របដណ្តប់ និងចំណុចផ្តោត ហើយនេះជាចំណុចដែលត្រូវពិចារណាមុនពេលអនុវត្ត។ បញ្ហាគឺមិនសូវមានទិន្នន័យចែកចាយជាសាធារណៈ។ គម្លាតមួយគឺចំណុចផ្តោត និងវិសាលភាពដែលមានគោលបំណងបង្កើននិរន្តរភាពបរិស្ថានរបស់សហគ្រាសខ្នាតមីក្រូ ខ្នាតតូច និងខ្នាតមធ្យមក្នុងវិស័យកាត់ដេរ ក៏ដូចជាឱកាស និងទិសដៅសម្រាប់ការងារនាពេលអនាគត។

ព័ត៌មានទំនាក់ទំនង

កាវិយាល័យ ILO ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិច
United Nations Building
Rajdamnern Nok Avenue
Bangkok 10200, Thailand

T: +66 2288 1234
F: +66 2280 1735
E: BANGKOK@ilo.org
W: www.ilo.org/asiapacific

©អង្គការអន្តរជាតិខាងការងារ ឆ្នាំ ២០២១